# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អធិប្បាយអំពីអធិបតេយ្យធម៌៣យ៉ាង គឺអត្តាធិបតេយ្យ លោកាធិបតេយ្យ និងធម្មាធិបតេយ្យ

**Website: www.hoksavann.org**

ថ្ងៃទី៨ មករា ២០០៥

អធិបតេយ្យធម៌៣យ៉ាងគឺ អត្តាធិបតេយ្យ ការយកខ្លួនជាធំ, លោកាធិបតេយ្យ ការយកលោកជាធំ និងធម្មាធិបតេយ្យ ការយកធម៌ជាធំ ទាំង៣នេះជាផ្នែកកុសល ។ សេចក្តីថា ការយកធម៌ទាំងបីនេះ ធម៌ណាមួយធ្វើជាធំ ជាមូលដ្ឋាន ដើម្បីប្រព្រឹត្តសាងខ្លួនឲ្យល្អ ។

១- អត្តាធិបតេយ្យ ដែលប្រែថាការយកខ្លួនជាធំ គឺមិនហ៊ានប្រព្រឹត្តអាក្រក់ដោយយកខ្លួនឯងជាធំ ដែលមានលក្ខណៈនៃការពិចារណា៤បែបគឺ ១- ជាតិបច្ចវេក្ខិត្វា ពុំហ៊ានប្រព្រឹត្តអាក្រក់ ដោយពិចារណាជាតិត្រកូលពូជអំបូរថា អាត្មាអញកើតមកមានជាតិត្រកូលពូជអំបូរវង្សត្រកូលតាំងពីជីដូនជីតាមក ធ្លាប់មានកេរ្តិ៍ឈ្មោះល្បី ថាជាត្រកូលមានពូជអំបូរល្អត្រឹមត្រូវ បើអាត្មាអញប្រព្រឹត្តធ្វើអំពើអាក្រក់ទៅ ហាក់ដូចជាបន្ថោកតម្លៃនៃវង្សត្រកូលដែលធ្លាប់ប្រព្រឹត្តល្អពីដើមមក ។ មួយទៀតពិចារណាថា អាត្មាអញបានកើតមកជាមនុស្សនេះ ចាត់ជាមានកំណើតប្រសើរជាងកំណើតសត្វតិរច្ឆាន គួរប្រព្រឹត្តមនុស្សធម៌ មិនគួរប្រព្រឹត្តធ្វើអំពើថោកទាបដែលផ្ទុយអំពីកំណើតថ្លៃថ្នូរនេះឡើយ ។ កាលបើពិចារណាឃើញដូច្នេះ ក៏មិនហ៊ានធ្វើអំពើបាប ។ ២- វយបច្ចវេក្ខិត្វា ពិចារណានូវវ័យឬអាយុរបស់ខ្លួនថា អាត្មាអញមានវ័យកាន់តែចាស់ហើយ មិនគួរប្រព្រឹត្តអំពើអាក្រក់ឡើយ ។ ក្នុងវ័យនេះ គួរសន្សំសេចក្តីល្អ ព្រោះសេចក្តីស្លាប់កាន់តែមកជិតហើយ ។ កាលបើពិចារណាឃើញដូច្នេះ ក៏លះបង់អំពើរបាប ។ ៣- សូរភាវំ បច្ចវេក្ខិត្វា ពិចារណានូវសេចក្តីក្លៀវក្លានិងយសស័ក្តិរបស់ខ្លួនថា អាត្មាអញជាអ្នកដឹកនាំគេ មានយសស័ក្តិ មានសេចក្តីក្លៀវក្លាគ្រប់ទីកន្លែង មានគេគោរពច្រើន គួរតែធ្វើចរិយាមារយាទឲ្យបានថ្លៃថ្នូរ ឲ្យបានល្អឡើងថែមទៀត ។ បើអាត្មាអញជាអ្នកដឹកនាំគេ បែរទៅប្រព្រឹត្តធ្វើអំពើថោកទាប ធ្វើឲ្យគេមានទុក្ខទៅវិញ ឈ្មោះថាអាត្មាអញសម្លាប់ខ្លួនឯងគឺសម្លាប់កិត្តិយសរបស់ខ្លួនទៅវិញ ព្រោះថា បើចង់បានសុខខ្លួនឯងទៅបៀតបៀនអ្នកដទៃ ពុំបានសេចក្តីសុខឡើយ ឈ្មោះថាជាអ្នកស្អប់ខ្លួនឯងទៅវិញ ព្រោះបានប្រព្រឹត្តធ្វើហេតុដែលនាំឲ្យមានទុក្ខដល់ខ្លួន ។ កាលបើពិចារណាដូច្នេះ ក៏វៀរចាកអំពើអាក្រក់ខ្មាស់មិនហ៊ានធ្វើ ។ ៤-ពហុស្សុច្ចំ បច្ចវេក្ខិត្វា ពិចារណានូវចំណេះចេះដឹងរបស់ខ្លួនថា អាត្មាអញបានរៀនសូត្រចេះដឹងច្រើន ជាអ្នកដឹងខុសដឹងត្រូវ ដឹងហេតុល្អហេតុអាក្រក់ គួរតែយកចំណេះចេះដឹងនេះ មកជួយខ្លួនឯងនិងជួយសង្គ្រោះអ្នកដទៃជាពិសេសជួយប្រទេសរបស់ខ្លួន ។ កាលបើពិចារណាដូច្នេះ ក៏មិនហ៊ានធ្វើអំពើបាប ។

លក្ខណៈនៃការពិចារណាទាំង៤បែបនេះ ជាអជ្ឈត្តិកសមុដ្ឋាន ប្រែថាយកខ្លួនឯងជាសមុដ្ឋានក្នុងការពិចារណា មិនធ្វើអំពើបាប ។ កន្លែងខ្លះហៅថា ហិរិ ប្រែថាខ្មាស់អំពើបាបមិនហ៊ានប្រព្រឹត្តធ្វើ ។

២- លោកាធិបតេយ្យ ប្រែថាយកលោកជាធំ គឺមិនហ៊ានធ្វើអំពើអាក្រក់ ដោយយកសង្គមមនុស្សជាធំ ដែលមានលក្ខណៈនៃការពិចារណា៤បែបគឺ ១- ពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ ព្រោះខ្លាចខ្លួនឯងទិតៀនខ្លួនឯងបាន ហើយអំពើអាក្រក់នាំឲ្យខ្លួនមានវិប្បដិសារី ក្តៅក្រហាយស្តាយក្រោយ ដោយសារតែកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តកន្លងមកហើយ ។ កាលបើពិចារណាដូច្នេះ ក៏បង្កើតស្មារតីប្រុងប្រយ័ត្ន មិនឲ្យអំពើអាក្រក់កើតឡើងបាន ។ ២-ពុំប្រព្រឹត្តអំពើអាក្រក់ ព្រោះខ្លាចសង្គមមនុស្ស ជាពិសេសលោកអ្នកសប្បុរសរិះគន់ ទោះបីអំពើអាក្រក់ធ្វើដោយគ្មានអ្នកណាដឹងក៏ដោយ ។ ៣- ពុំហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ ព្រោះខ្លាចមានទោសក្នុងបច្ចុប្បន្ន ដូចជាគេចាប់ធ្វើទោសធ្ងន់ស្រាលតាមកំហុសស្របតាមច្បាប់របស់រដ្ឋ ។ ៤- មិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ ព្រោះខ្លាចមានទោសក្នុងអនាគតជាតិ បានធ្លាក់ទៅសោយទុក្ខក្នុងនរកជាដើម ។ លក្ខណៈនៃការពិចារណាទាំង៤បែបនេះ ជាពហិទ្ធាសមុដ្ឋាន គឺយកអ្នកដទៃ ឬសង្គមមនុស្សខាងក្រៅខ្លួនឯង ជាសមុដ្ឋានក្នុងការពិចារណាមិនធ្វើអំពើបាប ។ កន្លែងខ្លះ ហៅថា ឱត្តប្បៈ គឺខ្លាចអំពើបាបមិនហ៊ានប្រព្រឹត្តធ្វើ ។

៣- ធម្មាធិបតេយ្យ ប្រែថាយកធម៌ជាធំ គឺមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយយកធម៌ជាធំ ។ ធម៌ក្នុងទីនេះ សំដៅយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលជាតួពុទ្ធវចនៈ រួមដោយសេចក្តីសង្ខេបមាន៣យ៉ាងគឺការហាមមិនឲ្យធ្វើអំពើអាក្រក់, ឲ្យបំពេញសេចក្តីល្អ និងការជំនះចិត្តឲ្យស្អាតបរិសុទ្ធ ។ ដោយពិចារណាថា ធម៌ដែលព្រះពុទ្ធសំដែងហើយ ជាសច្ចធម៌ ជាធម៌នាំមនុស្សសត្វដែលប្រតិបត្តិឲ្យចេញចាកទុក្ខ ។ កាលបើមានជំនឿយ៉ាងមាំក្នុងព្រះធម៌នេះហើយ ទើបពុំប្រព្រឹត្តធ្វើនូវអំពើណាដែលខុសផ្លូវធម៌ ។ ធម្មាធិបតេយ្យ ជាច្បាប់ធម្មជាតិសកល ដែលរកឃើញដោយព្រះសម្មាសម្ពុទ្ធ ឯច្បាប់ផ្លូវលោកកើតឡើងពីមនុស្សរបស់រដ្ឋនីមួយៗព្រមព្រៀងគ្នាបង្កើតឡើង សំរាប់សង្គមរៀងៗខ្លួន ពុំមែនជាច្បាប់មានការពិតសកលឡើយ ។ ច្បាប់ផ្លូវធម៌មានការពិតផង រំដោះទុក្ខមនុស្សសត្វផង ហើយនៅទីកន្លែងណា នៅពេលវេលាណា ក៏អាចយកទៅអនុវត្តបាន ។ ដូច្នេះបើមនុស្សសត្វយកព្រះធម៌ជាធំ អនុវត្តតាមតែព្រះធម៌ នោះគេនឹងបានសេចក្តីសុខចំរើនក្នុងជីវភាពបច្ចុប្បន្ន ហើយនិងបានសំរេចព្រះនិព្វាន រួចចាកទុក្ខ មានជាតិទុក្ខជាដើមក្នុងអវសានជាតិ ។៚

❑